# ការចេញផ្សាយពត៌មាន

**“ធ្វើការលំបាកជាងមុនប្តូរនឹងកម្រៃតិចជាងមុន”**

**ផលប៉ះពាល់នៃការបញ្ចប់កិច្ចព្រមព្រៀងពហុសរសៃ   មកលើកម្មករ-កម្មការិនីកម្ពុជា**

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៦ ដែលជាទិវាពលកម្មអន្តរជាតិ កម្មករ-កម្មការិនីកាត់ដេរកម្ពុជា រួមគ្នាលាតត្រដាងពីផលប៉ះពាល់នៃការបញ្ចប់កិច្ចព្រមព្រៀងពហុសរសៃ（MFA） មកលើជីវិតរបស់កម្មករកម្មការិនីកាត់ដេរកម្ពុជា។ នៅខណៈដែលផលប៉ះពាល់ជាច្រើននៃការបញ្ចប់កូតាស្តែងចេញយ៉ាងច្បាស់ គឺក្រៅពីការបាត់បង់ការងាររបស់កម្មករ ការផ្លាស់ប្តូរនៃល័ក្ខខ័ណ្ឌការងារ រួមទាំងការធ្លាក់ចុះនៃប្រាក់ចំណូលរបស់កម្មករ-កម្មការិនីមួយភាគធំ ទំនាក់ទំនងសង្គមក៏បានស្តែងចេញយ៉ាងទូលំទូលាយអំពីបញ្ហាខាងសុខភាពផ្លូវកាយនឹងផ្លូវចិត្ត។

យោងតាមរបាយការថ្មីៗមួយចំនួន ក្រៅពីកំណើនផលិតភាពនៃវិស័យកាត់ដេរចំនួន ៦.៥ភាគរយក្នុងឆ្នាំ២០០៥ ការបែងចែកប្រាក់ចំណូលដែលមិនស្មើភាពគ្នា និងការធ្លាក់ចុះនៃតម្លៃនៃសម្លៀកបំពាក់នាំចេញ បានបង្ហាញថាប្រាក់ ចំណូលរបស់កម្មករមានការធ្លាក់ចុះប្រមាណ៥ភាគរយក្នុងឆ្នាំ២០០៥។ ទោះបីជាការនាំចេញសម្លៀកបំពាក់ និងចំនួនកម្មករមានការកើនឡើងក្នុងឆ្នាំ២០០៥ក៏ដោយ ក៏តម្លៃនាំចេញមានការធ្លាក់ចុះចំនួន៦ភាគរយដែរ។ នៅក្នុងបរិបទនៃការបញ្ចប់កូតា មានសម្ពាធដ៏ធ្ងន់មួយមកលើរោងចក្រក្នុងការបង្កើនផលិតភាពនិងបញ្ចុះតម្លៃផលិតនានា។ ដូច្នេះកម្មករ ត្រូវធ្វើការរយៈពេលច្រើនម៉ោង  និងលំបាកជាងមុនតែទទួលកម្រៃតិច មានន័យថាពួកគេក្រីក្រជាងមុនតែធ្វើការលំបាក ជាងមុន។

នៅតាមមណ្ឌលកម្មករទាំងប្រាំមួយកន្លែងដែលមានមូលដ្ឋាននៅភ្នំពេញ ដែលមានកម្មករជាអ្នកដំណើរការមណ្ឌលនេះ រួមជាមួយនឹងអង្គការស្រ្តីដើម្បីការផ្លាស់ប្តូរ ករណីសិក្សាជាច្រើន និងទិន្ន័យដែលបាននិងនៅតែបន្តប្រមូលដោយក្រុមកម្មករសកម្មបង្ហាញថា ក្នុងបរិបទនៃលក្ខណ្ឌការងារដ៏អាក្រក់ទាំងនេះ រោងចក្រជាច្រើនបានប្រើប្រាស់យុទ្ធសាស្រ្តគ្រប់គ្រងថ្មី ដែលកម្មករក្លាយជាកម្មវត្ថុនៃការគំរាមកំហែងក្នុងការបណ្តេញចេញពីការងារដែលកាន់តែមានការកើនឡើង ការកើនឡើងនូវការប្រកួតប្រជែងរវាងកម្មករម្នាក់ៗ  និងការធ្លាក់ចុះនៃការគោរពសិទ្ធិកម្មករ ពីព្រោះសកម្មភាព សហជីពត្រូវបានគេបង្ក្រាប។

**"នៅមុនពេលបញ្ចប់កិច្ចព្រមព្រៀងពហុសរសៃ ខ្ញុំត្រូវដេរ៣00 ឱ្យហើយក្នុងរយៈពេល៨ម៉ោង ហើយដេរតែម៉ាស៊ីនមួយទេ ប៉ុន្តែឥឡូវនេះខ្ញុំត្រូវបានគេកំនត់ឱ្យដេរពី៥៥0ទៅ៦00 ក្នុងរយៈពេល៨ម៉ោងដូចគ្នា ហើយដេរម៉ាស៊ីនពីរ ។ ប្រធានក្រុមប្រាប់ខ្ញុំថា ខ្ញុំត្រូវតែយល់ព្រមធ្វើការងារនេះ" ។** កម្មករមកពីរោងចក្រមួយនៅភ្នំពេញ ដែលដេរម៉ាក់ Old Navy ( ករណីសិក្សាលើកម្មកររបស់ W.A.C ឆ្នាំ២00៥) ។

ថ្វីបើឧស្សាហកម្មកាត់ដេរនៅតែជាវិស័យដែលរកចំណូលច្រើនជាងគេដោយការនាំចេញសំលៀកបំពាក់ ព្រមទាំងជាវិស័យដ៏សំខាន់ដែលគាំទ្រទៅលើកំណើនផលិតផលក្នុងស្រុករបស់កម្ពុជា នាឆ្នាំ២00៥ ដែលអត្រាកំណើនដែលប៉ាន់ស្មាន គឺប្រមាណ៩.៨ភាគរយក៏ដោយ កម្មករ-កម្មការិនីកាត់ដេរកម្ពុជាពុំបានទទួលនូវផលប្រយោជន៍សមស្របនោះទេ ។ ដើម្បីធានាឱ្យបាននូវនិរន្តភាពនៃឧស្សាហកម្មកាត់ដេរសំរាប់ធ្វើជាខ្សែជីវិតដ៏សំខាន់នៃសេដ្ឋកិច្ចកម្ពុជា ឧស្សាហកម្ម ស្ថាប័នរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវតែកំណត់ឱ្យបាន និងដោះស្រាយនូវផលប៉ះពាល់អវិជ្ជមាននៃការបញ្ចប់កូតា មកលើ ជីវភាពកម្មករ-កម្មការិនីកាត់ដេរកម្ពុជា ដើម្បីអោយល័ក្ខខ័ណ្ឌការងារ កម្រៃ និងសិទ្ធិកម្មករមានភាពប្រសើរឡើង ។

**សមាជិកនៃស្ថាប័នសារពត៌មាន ត្រូវបានអញ្ជើញឱ្យបញ្ជូនភ្នាក់ងារសារពត៌មានមកចូលរួមសន្និសិទកាសែតនេះ**

*នៅទីស្នាក់ការ អង្គការស្ត្រីដើម្បីការផ្លាស់ប្តូរ អាសយដ្ឋានផ្ទះលេខ១ វិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ (អតីតរង្គសាល បណ្តែតទឹកគង្គា ទល់មុខក្រុមហ៊ុនកាំមីនតែល)*

*ពេលវេលា: ម៉ោង បីរសៀល*

**សំរាប់ពត៌មានទំនាក់ទំនង: កញ្ញា ព្រំ ផល្លីន (0១២ ២២៩ ៥៥៤) និង**

**កញ្ញា ចាន់ លីណែត (0១៦ ៩៩៦ 0២២)**